គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

លេខ..០៤១៣/០៩...គ.ស.ម

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩

# សេចក្តីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថាពេលវេលាសមល្មមបានមកដល់ហើយ **ក្រោយពីយើងបង្កើតចលនាលទ្ធិប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ** នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ដែលអ្នកជាតិនិយម អ្នកប្រជាធិបតេយ្យសេរីនិយមទាំងអស់គប្បីជួបជុំគ្នាអង្គុយពិភាក្សាគ្នាដោយតម្លាភាព យកប្រយោជន៍ជាតិជាធំបង្កើតឱ្យបាននូវគណបក្សនយោបាយថ្មីមួយស្របតាមការទាមទាររបស់ប្រជាពលរដ្ឋខ្មែរ ។

អស់រយៈពេលប្រមាណមួយឆ្នាំបន្ទាប់ពីការបោះឆ្នោតអាណត្តិទី៤កន្លងទៅនេះ សាធារណមតិជាច្រើនមានការព្រួយបារម្ភចំពោះស្ថានភាពនយោបាយ អធិបតេយ្យភាព បូរណភាពទឹកដី ប្រជាធិបតេយ្យ សេរីភាពសម្តែងមតិ ព្រមទាំងបញ្ហាសេដ្ឋកិច្ច និងសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការធ្លាក់ចុះ ដោយអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ។

តាមរយៈការចុះជួបដោយផ្ទាល់របស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សនៅតាមមូលដ្ឋានភូមិ-ឃុំជាច្រើននៅក្នុងប្រទេស ក៏ដូចជាតាមរយៈទស្សនកិច្ចនៅក្រៅប្រទេសកន្លងទៅនេះ ប្រជាពលរដ្ឋខ្មែរអ្នកស្នេហាជាតិ អ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យសេរីជាច្រើនបានទាមទារឱ្យគណបក្សនយោបាយ និងអ្នកនយោបាយខ្មែរទាំងឡាយណាដែលតាំងខ្លួនថាជាអ្នកជាតិនិយម ឬប្រជាធិបតេយ្យនិយមទាំងអស់ឱ្យរួបរួមគ្នាបង្កើតជា គណបក្សនយោបាយថ្មីតែមួយដើម្បីឈានទៅយកជ័យជំនះក្នុងការបោះឆ្នោតនាពេលខាងមុខនេះ ។

**គណបក្សសិទ្ធិមនុស្ស** សូមបញ្ជាក់សាជាថ្មីម្តងទៀតនូវគោលជំហររបស់ខ្លួនជូនសាធារណជនជ្រាបថា គណបក្សសិទ្ធិមនុស្សបានសម្រេចត្រៀមខ្លួនរួចជាស្រេចហើយក្នុងការរួបរួមជាមួយគណបក្ស ឬអ្នកនយោបាយដែលជាអ្នកជាតិនិយម អ្នកប្រជាធិបតេយ្យទាំងឡាយ ដើម្បីបង្កើតឱ្យបានជាដាច់ខាត**គណបក្សនយោបាយថ្មី**មួយឈរលើមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ។

គណបក្ស សិទ្ធិមនុស្ស H.R.P. HUMAN RI...

*សម្រាប់ព័ត៌មានបន្ថែមទាក់ទង*

*លេខទូរស័ព្ទ : ០១៦ ៤៣៥ ១០៦*

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info